**ASIAN AMERICAN LEGAL DEFENSE AND EDUCATION FUND**
99 HUDSON STREET, 12 FL • NEW YORK. NY 10013 • TEL 212.966.5932 • FAX 212.966.4303 • INFO@AALDEF.ORG

# អ្វីដែលអ្នកគួរដឹង
# អំពីការជំរឿនឆ្នាំ 2010

ខែ សីហា ឆ្នាំ 2009

- ដោយត្រូវបានធ្វើឡើងរៀងរាល់ 10 ឆ្នាំម្តង ការជំរឿនផ្តល់នូវទិន្នន័យដែលត្រូវបានប្រើប្រាស់ដើម្បីអនុវត្តគោលនយោបាយនានាដែលមានឥទ្ធិពលទៅលើសហគមន៍អាមេរិក-អាស៊ី ដោយរួមមាន :
  - ការផ្តល់ប្រាក់ជាង 300 ពាន់លានដុល្លាសហរដ្ឋអាមេរិកនៅក្នុងមូលនិធិរបស់សហព័ន្ធទៅអោយរដ្ឋ និង សហគមន៍ទាំងឡាយសម្រាប់យកទៅប្រើប្រាស់ក្នុងសេវាសង្គមនានាដូចជា ថ្នាក់រៀន ESL ការបណ្តុះបណ្តាលការងារ និង សេវាអ្នកបកប្រែ
  - ការអនុវត្តច្បាប់ស្តីពីសិទ្ធិពលរដ្ឋនៅក្នុងការអប់រំ ការងារ ការថែទាំសុខភាព ការស្នាក់នៅ អន្តោប្រវេសន៍ ការខ្ចីប្រាក់ និង ការបោះឆ្នោត
  - លទ្ធភាពទទួលបានសន្លឹកឆ្នោតជាពីរភាសា
  - ការបែងចែកអាសនៈសភាទៅអោយរដ្ឋទាំងឡាយ និង ការកំណត់នៃការតំណាងផ្នែកនយោបាយរបស់ក្រុមជន ជាតិភាគតិច និងសញ្ជាតិនានា ។

- ព័ត៌មានដែលអ្នកផ្តល់អោយក្នុងការជំរឿននេះត្រូវបានរក្សាទុកដោយសម្ងាត់បំផុត ។ យោងទៅតាមច្បាប់ ព័ត៌មានឯកជនរបស់អ្នកមិនអាចចែករំលែកជាមួយនឹង USCIS, ICE, IRS ប៉ូលីស ម្ចាស់ផ្ទះ ឬ អ្នកជិតខាងបានឡើយ ។
- កំរងសំនួរនៃការជំរឿនឆ្នាំ 2010 នេះគ្រាន់តែសួរនូវសំនួរងាយៗមួយចំនួនតែប៉ុណ្ណោះ – ឈ្មោះ ទំនាក់ទំនង ភេទ អាយុ និង ថ្ងៃខែឆ្នាំកំណើត ជាតិសាសន៍ និង សួរថាតើអ្នកមានផ្ទះផ្ទាល់ខ្លួន ឬកជួលគេ ។ ប៉ុន្តែកំរងសំនួរនៃការជំរឿនផ្សេងទៀត ជាក់លាក់ (ការស្ទាបស្ទង់សហគមន៍អាមេរិក – American Community Survey) នឹងសួរអំពីការទទួលបានសញ្ជាតិ ប្រាក់ចំណូល ដើមកំណើត និង ភាពស្ទាត់ជំនាញភាសាអង់គ្លេស ។ ជំរឿនមិនដែលសួរអំពីស្ថានភាពអន្តោប្រវេសន៍ឡើយ ។
- នៅចន្លោះខែ កុម្ភៈ និង ខែ មីនា ឆ្នាំ 2010 អ្នកនឹងទទួលបានកំរងសំនួរនៃការជំរឿនតាមសំបុត្រ ។ សូមបំពេញវាអោយបានត្រឹមត្រូវតាមតែអាចធ្វើទៅបាន និងផ្ញើវាតាមសំបុត្រមកវិញ ។ តែមប្រៃសណីយ៍ត្រូវបានបង់ប្រាក់ជាមុន ។ ប្រសិនបើអ្នកមិនបានទទួលកំរងសំនួរតាមសំបុត្រ អ្នកអាចយកទម្រង់ពាក្យ "ត្រូវបានរាប់បញ្ចូល - Be Counted" នៅតាមទីតាំងសហគមន៍ទាំងឡាយ ។
- នៅចន្លោះខែ មេសា និង កក្កដា ឆ្នាំ 2010 អ្នកធ្វើជំរឿន ("បុគ្គលិកជំរឿន") នឹងដើរតាមផ្ទះនៅក្នុងសង្កាត់របស់អ្នក ដើម្បីបន្តតាមដានគ្រួសារទាំងឡាយ ។ ដំណើរការនេះ នឹងរួមមានចំណុចទាំងឡាយដូចខាងក្រោម :
  - ដំបូង អ្នកធ្វើជំរឿននឹងចុះទៅតាមផ្ទះទាំងឡាយដែលមិនទាន់បានផ្តល់ទម្រង់ពាក្យជំរឿនតាមសំបុត្រមកវិញ ។ ប្រសិនបើពួកគេមិនអាចទទួលបានព័ត៌មានពីសមាជិកណាម្នាក់នៅក្នុងគ្រួសារ ពួកគេនឹងចុះទៅសួរផ្ទះជិតខាង ។
  - ទីពីរ អ្នកធ្វើជំរឿននឹងចុះទៅតាមផ្ទះទាំងឡាយដែលបានប្រគល់ទម្រង់ពាក្យជំរឿនអោយ ដើម្បីបញ្ជាក់ថាវាពិតជាត្រូវបានបំពេញយ៉ាងត្រឹមត្រូវ ។
  - ទីបី អ្នកធ្វើជំរឿននឹងផ្ទៀងផ្ទាត់ព័ត៌មានដែលបានផ្តល់ឱ្យដោយមនុស្សម្នាក់ ដែលបានទម្រង់ពាក្យ "ត្រូវបានរាប់បញ្ចូល - Be Counted" ដែលត្រូវបានប្រមូលយកតាមទីតាំងក្នុងសង្កាត់ ។

- អ្នកធ្វើជំរឿន អាចចុះតាមគ្រួសារមួយច្រើនជាងមួយដង ។ សូមជួយសហការ និង ឆ្លើយសំនួររបស់ពួកគេ ។ នេះគឺដើម្បីធានាអោយមានការរាប់ចំនួនបានត្រឹមត្រូវ ។

- ប្រសិនបើអ្នកមិនយល់ភាសាអង់គ្លេស អ្នកនៅតែអាចត្រូវបានរាប់!
  - សូមទូរស័ព្ទមកកាន់មជ្ឈមណ្ឌលផ្តល់ជំនួយឆ្លើយកំរងសំនួរជំរឿនតាមទូរស័ព្ទ [Telephone Questionnaire Assistance (TQA) Center] ដែលនឹងចាប់ផ្តើមបើកពីថ្ងៃទី 25 ខែ កុម្ភៈ ឆ្នាំ 2010 រហូតដល់ ថ្ងៃទី 30 ខែ កក្កដា ឆ្នាំ 2010។ លេខទូរស័ព្ទគឺ 1-866-872-6868។ ពួកគេមានមនុស្សដែលអាចនិយាយ ភាសារបស់អ្នកបាន។
    - អ្នកអាចបំពេញទម្រង់ពាក្យជំរឿនតាមទូរស័ព្ទ ហើយអ្នកតំណាងនៃការជំរឿន អាចឆ្លើយសំនួរបន្ថែមណាមួយ។
    - អ្នកអាចស្នើសុំក្រដាសកំរងសំនួរជំរឿនថតចម្លងជាភាសាចិន កូរ៉េ វៀតណាម អេស្ប៉ាញ ឬ ភាសារុស្ស៊ី។
    - ចុងក្រោយ ប្រសិនបើអ្នកត្រូវការជំនួយជាភាសាផ្សេងទៀតក្រៅពីភាសាទាំងឡាយដែលមានរាយបង្ហាញ អ្នកក៏អាចស្នើសុំសៀវភៅណែនាំជំនួយភាសា (Language Assistance Guide ) ផងដែរ។
  - សូមទូរស័ព្ទមកកាន់ ការិយាល័យជំរឿនក្នុងតំបន់របស់អ្នក និង ស្នើសុំអ្នកធ្វើជំរឿនដែលអាចនិយាយភាសារបស់អ្នក ដើម្បីមកផ្ទះរបស់អ្នក។ លេខទូរស័ព្ទទាំងនេះ នឹងត្រូវបានផ្តល់អោយឆាប់បំផុតតាមដែលអាចមាន ។

- ប្រសិនបើអ្នកមិនច្បាស់ថាតើអ្នកដែលចុះមកផ្ទះរបស់អ្នក ជាអ្នកធ្វើជំរឿន ឬអត់ នោះ
  - សុំអោយគាត់/នាងបង្ហាញពីកាតសំគាល់ "បុគ្គលិកជំរឿន" ដែលចេញដោយរដ្ឋាភិបាលសហព័ន្ធ។ អ្នកធ្វើជំរឿនក៏អាចយួរកាបូបពណ៌ខ្មៅមួយដែលមានឈ្មោះអក្សរបោះពុម្ពធំៗថា "ជំរឿនឆ្នាំ 2010 (Census 2010)" ។
  - ប្រសិនបើអ្នកនៅតែមានការព្រួយបារម្ភ អ្នកអាចទូរស័ព្ទមកកាន់មជ្ឈមណ្ឌលជំរឿនប្រចាំតំបន់ (Regional Census Center) របស់អ្នក ដើម្បីបញ្ជាក់ថាមនុស្សម្នាក់នោះ ត្រូវបានជួលអោយបម្រើការងារដោយការិយាល័យជំរឿនសហរដ្ឋអាមេរិក (U.S. Census Bureau) មែនដែរឬអត់ ។

- ប្រសិនបើអ្នកធ្វើជំរឿនណាមួយ សំដែងអាកប្បកិរិយាមិនសមរម្យ ឬ បង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក សូមទូរស័ព្ទមកកាន់ AALDEF ភ្លាមៗតាមលេខទូរស័ព្ទ 212-966-5932។AALDEF នឹងត្រួតពិនិត្យសកម្មភាពនានារបស់ការិយាល័យជំរឿននៅក្នុងរដ្ឋទាំងឡាយ។ យើងនឹងរាយការណ៍ពីបណ្តឹងនៃការប្រព្រឹត្តិមិនសមរម្យ ឬ ការចែករំលែកព័ត៌មានផ្ទាល់ខ្លួនណាមួយ។ មេធាវីរបស់ AALDEF ក៏នឹងការពារសិទ្ធិឯកជនភាពរបស់អ្នក ជាពិសេសប្រសិនបើអ្នកមិនមានសំណុំលិខិតអន្តោប្រវេសន៍។

**ដោយមានហានិភ័យច្រើន ការរាប់ចំនួនត្រឹមត្រូវនៃសហគមន៍អាមេរិក-អាស៊ី ពិតជាមានសារៈសំខាន់!**
**សូមចូលរួមនៅក្នុងការជំរឿន!**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:

Asian American Legal Defense & Education Fund (AALDEF)
99 Hudson Street, 12th Floor ▪ New York, NY 10013
800.966.5946 ▪ info@aaldef.org ▪ www.aaldef.org

© 2009 AALDEF – Census Fact Sheet – Khmer